# រកបានប្រាក់ដុល្លារ SNAP

## ពីប្រាក់រង្វាន់លើកទឹកចិត្តសុខភាពល្អ (Healthy Incentives Program)!

ចំណាយប្រាក់ដុល្លារ **SNAP** របស់អ្នកទៅលើផ្លែឈើនិងបន្លែស្រស់បាន ពីកសិដ្ឋាននៅកន្លែងលក់រាយនៃកម្មវិធីប្រាក់រង្វាន់លើកទឹកចិត្តសុខភាពល្អ **(HIP)** ហើយត្រូវបានគេបន្ថែមចំនួនប្រាក់នៃការជាវរបស់អ្នក ចូលវិញភ្លាមៗទៅក្នុងប័ណ្ណ **EBT** របស់អ្នក!

### ទីផ្សាររបស់កសិករ

វែងរកមើលកសិករដែលចូលរួមក្នុងកម្មវិធីនៅទីផ្សារដែលត្រូវបានកំណត់ពេលបើកយ៉ាងទៀងទាត់ នៅក្នុងទីប្រជុំជនរបស់អ្នកឬក្បែរខាង ដែលលក់ផ្លែឈើនិងបន្លែស្រស់។



### តូបកសិដ្ឋាន

ហាងនៅនឹងកសិដ្ឋានដែលអ្នកអាចទិញផ្លែឈើនិងបន្លែស្រស់ ដែលបានដោយផ្ទាល់ពីដៃដែលបេះពួកវា។





### ទីផ្សារចល័ត

ទីផ្សារដែលនាំយកផលិតផលស្រស់ៗនៃកសិដ្ឋានចូលទៅកាន់សហគមន៍របស់អ្នកផ្ទាល់តែម្តង។



### ភាគហ៊ុនកសិដ្ឋាន CSA

សេវាកម្មដែលផ្អែកលើសមាជិកភាពដែលផ្តល់ដល់ក្រុមគ្រួសារអ្នកនូវផ្លែឈើនិងបន្លែស្រស់រៀងរាល់សប្តាហ៍។

### មើលចំនួនប្រាក់ដែលអ្នកអាចរកបានក្នុងខែនីមួយៗ! (ដោយផ្អែកលើទំហំគ្រួសារ)

**$40** សមាជិកគ្រួសារ 1-2 នាក់ | **$60** សមាជិកគ្រួសារ 3-5 នាក់ | **$80** សមាជិកគ្រួសារ 6+ នាក់

HIP-Flyer-KH (Rev. 8/2025) 09-001-0625-06

Khmer, ភាសាខ្មែរ

# វែងរកទីតាំងកម្មវិធី HIP ដែលនៅក្បែរអ្នក

សូមចូលទៅកាន់គេហទំព័រ www.mass.gov/hip រកមើលបញ្ជីរាយនាមនិងអាសយដ្ឋានទំនាក់ទំនង ហៅមកកាន់បណ្ដាញទូរស័ព្ទទាន់ហេតុការណ៍នៃ Project Bread's FoodSource តាមរយៈលេខ 1-800-645-8333 ឬស្វែងរកនិមិត្តសញ្ញាតំណាងកម្មវិធី HIP។

## តើកម្មវិធី HIP ធ្វើការដំណើរការយ៉ាងដូចម្ដេច?












**1**

អ្នកត្រូវបានចុះឈ្មោះរួចហើយ! ប្រើប្រាស់ប្រាក់ដុល្លារ SNAP របស់អ្នកដើម្បីទិញផ្លែឈើនិងបន្លែស្រស់ពីកសិដ្ឋាននៅកន្លែងលក់រាយនៃកម្មវិធី HIP។

**2**

ចំនួនសមមូលនៃលុយ ក្នុងចំនួនរហូតដល់កម្រិតដែនកំណត់ប្រចាំខែរបស់អ្នក ត្រូវបានបន្ថែមចូលវិញភ្លាមៗទៅក្នុងប័ណ្ណ EBT របស់អ្នក។

**3**

បង្កាន់ដៃរបស់អ្នកនឹងបង្ហាញនូវចំនួននៃប្រាក់ដុល្លារ SNAP បន្ថែមដែលអ្នករកបាន។

**4**

ចំណាយអត្ថប្រយោជន៍ដែលរកបានរបស់អ្នកនៅគ្រប់ទីកន្លែងដែលទទួល SNAP។


*គាំទ្រជ្រោមជ្រែងដោយ USDA FINI និងរដ្ឋ Massachusetts ។*

HIP-Flyer-KH (Rev. 8/2025)
09-001-0625-06